មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការផ្អាកសវនាការដោយសារការអនុវត្តន៍

# «សិទ្ធិមានវត្តមានក្នុងសវនាការ»

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ លោកចៅក្រម និល ណុន ជាប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកាសបើកសវនាការស្តាប់សក្ខីកម្មសាក្សី ឆោម សែ ប្រឆាំងនឹងជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ក្នុងសំណុំរឿង០០២ ។ ប៉ុន្តែសវនាការត្រូវបានប្រកាសបិទវិញ និងពន្យារពេលរហូតដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣ បន្ទាប់ពីមេធាវីការពារក្តីជនជាប់ចោទ នួន ជា ស្នើសុំផ្អាកសវនាការមួយរយៈ ដោយសារកូនក្តីរបស់ខ្លួនមានបញ្ហាសុខភាពមិនអាចចូលរួមសវនាការបាន ។ មេធាវីអន្តរជាតិ វ៉ិចទ័រកូប៉េ បានបញ្ជាក់ថា កូនក្តីរបស់ខ្លួនត្រូវបានបញ្ជូនទៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ដើម្បីទទួលការសង្គ្រោះបន្ទាន់ បន្ទាប់ពីបានដួលនៅមន្ទីរឃុំឃាំង ។ បន្ថែមលើនេះទៀត របាយការណ៍មកពីមន្ទីរពេទ្យបានបញ្ជាក់ថា នួន ជា មានជំងឺរលាកទងសួត មានលក្ខណៈស្រួចស្រាល់និងដើងទាំងពីរមានការចុះខ្សោយខ្លាំង ។ដូច្នេះគម្រូវឲ្យសម្រាកនៅមន្ទីរពេទ្យរយៈពេលពី៤ទៅ ៧ ថ្ងៃ ដើម្បីទទួលការពិនិត្យតាមដាន និងព្យាបាលជំងឺ ។

មេធាវីការពារក្តីបានលើកឡើងអំពីសិទ្ធិរបស់ជនជាប់ចោទ នួន ជា ក្នុងការទទួលបានសវនាការមួយ ដែលត្រូវប្រព្រឹត្តទៅដោយមានវត្តមានរបស់ខ្លួន មកធ្វើជាមូលដ្ឋានច្បាប់ក្នុងការស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។ គួរបញ្ជាក់ថា ចាប់ពីពេលដែលជនជាប់ចោទ នួន ជា ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ រហូតមកដល់ថ្ងៃបើកសវនាការនេះ មេធាវីការពារក្តីនៅមិនទាន់បានជួប និងទទួលបានការបញ្ជាក់ពីជនជាប់ចោទ នួន ជា អំពីជំហររបស់ខ្លួនក្នុងការអនុវត្ត ឬបោះបង់ចោលនូវសិទ្ធិមានវត្តមានក្នុងសវនាការនៅឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ លោកមេធាវី វ៉ិចទ័រកូប៉េ បានអះអាងថា ក្នុងករណីនេះសច្ចធានៃច្បាប់បានសន្មត់ថា ជនជាប់ចោទ នួន ជា មិនបានលះបង់សិទ្ធិមានវត្តមានក្នុងសវនាការឡើយ ។ ដូច្នេះសវនាការមិនអាចប្រព្រឹត្តទៅដោយអវត្តមានជនជាប់ចោទ នួន ជា ឡើយ ។ អ្វីដែលកាន់តែរឹងមាំជាងនេះទៀតនោះ ភាគីទាំងអស់ ដែលរួមមាន តំណាងសហព្រះរាជអាជ្ញា ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីជនជាប់ចោទផ្សេងៗទៀត បានគាំទ្រចំពោះសំណើ និងអំណះអំណាងរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

គួរបញ្ជាក់ថា ដោយអនុលោមតាមគោលការណ៍ចំពោះមុខ វិធាន ៨១ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានតម្រូវឲ្យការជម្រះក្តីនៅក្នុងតុលាការនេះ ត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ ។ លើកលែងតែៈ

ទី១) ក្រោយពេលបង្ហាញខ្លួនជាលើកដំបូង និងបានទទួលដីកាកោះដោយត្រឹមត្រូវសម្រាប់ចូលរួមក្នុងសវនាការជាបន្តបន្ទាប់ ប្រសិនបើជនជាប់ចោទនៅតែបន្តបដិសេធ ឬខកខានមិនបានចូលរួម ឬត្រូវបានបណ្តេញចេញពីកិច្ចដំណើរការនីតិវិធី នោះអង្គជំនុំជម្រះអាចដំណើរការនីតិវិធីដោយអវត្តមានជនជាប់ចោទបាន ។ ក្នុងករណីនេះ អង្គជំនុំជម្រះត្រូវចាត់តាំងមេធាវីសម្រាប់ការពារជនជាប់ចោទ ។

ទី២) នៅពេលដែលមានមូលហេតុសុខភាព ឬមូលហេតុធ្ងន់ធ្ងរដ៏ទៃទៀត ដែលជនជាប់ចោទមិនអាចចូលរួមដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះបាន អង្គជំនុំជម្រះអាចបន្តនីតិវិធីដោយអនុញ្ញាតឲ្យជនជាប់ចោទចូលរួមតាមរយៈប្រព័ន្ធសោតទស្សន៍បាន ។ ប៉ុន្តែក្នុងករណីនេះជនជាប់ចោទត្រូវមាន រូបកាយនិងស្មារតីសមស្របអាចចូលរួមក្នុងដំណើរការនីតិវិធីបាន ហើយជនជនជាប់ចោទបានយល់ព្រមលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅបន្ទប់សវនាការ ឬនៅពេលដែលអវត្តមានរបស់ជនជាប់ចោទឈានដល់កម្រិតមួយដែលបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរ ហើយនៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវតែប៉ុណ្ណោះ ។

សរុបសេចក្តីមក ក្នុងករណីជនជាប់ចោទមានបញ្ហាសុខភាពមិនអាចចូលរួមតាមដានកិច្ចដំណើរការសវនាការបានហើយជនជាប់ចោទមិនបានលះបង់ «សិទ្ធិមានវត្តមានក្នុងសវនាការ» នោះអង្គជំនុំជម្រះមិនអាចបន្តនីតិវិធីដោយអវត្តមានជនជាប់ចោទបានឡើយ ។ គួរបញ្ជាក់ថា សិទ្ធិមានវត្តមានក្នុងសវនាការគឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិជាមូលដ្ឋានសំខាន់ៗ ផ្សេងទៀតដែលត្រូវបានធានាសម្រាប់បុគ្គលរូបដើម្បីទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវ និងយុត្តិធម៌ ។ ដូច្នេះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងក្លាយជាគំរូដ៏ល្អមួយសម្រាប់តុលាការ និងការអនុវត្តច្បាប់នៅកម្ពុជាកាន់តែមានភាពប្រសើរឡើង ។

**ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣**

**ចាន ប្រាថ្នា**